## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៣៣..សសរ..

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី ៥ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

### ប្រការ ១.-

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី ៥ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម ញ៉ុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម សក់ សេដ្ឋា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | អនុប្រធាន |
| ៤-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៥-រដ្ឋលេខាធិការក្រសួងការពារជាតិ | | សមាជិក |

| | |
|---|---|
| ៦-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-អនុប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន | សមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៤-ឯកឧត្តម **សៀង ឡាប្រេស្ស** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៥-អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦-អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧-អភិបាលខេត្តកំពង់ចាម | សមាជិក |
| ១៨-អភិបាលខេត្តព្រៃវែង | សមាជិក |
| ១៩-អភិបាលខេត្តស្វាយរៀង | សមាជិក |
| ២០-អភិបាលខេត្តកណ្តាល | សមាជិក |
| ២១-អភិបាលខេត្តក្រចេះ | សមាជិក |
| ២២-អភិបាលខេត្តតាកែវ | សមាជិក |
| ២៣-អភិបាលខេត្តព្រះសីហនុ | សមាជិក |
| ២៤-អភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ២៥-អភិបាលខេត្តរតនគិរី | សមាជិក |
| ២៦-អភិបាលខេត្តកំពត | សមាជិក |
| ២៧-អភិបាលខេត្តកែប | សមាជិក |

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួង មានភារកិច្ចដូចខាងក្រោម ÷

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់គណៈប្រតិភូកម្ពុជា ដែលដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមក្នុងកិច្ចប្រជុំលើកទី ៥ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ពិភាក្សា និងសម្របសម្រួលជាមួយក្រុមការងារវៀតណាម ដើម្បីរៀបចំខ្លឹមសារនានាសម្រាប់កិច្ចប្រជុំលើកទី ៥ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ឱ្យដំណើរការបានលទ្ធផលល្អប្រសើរ
- រៀបចំគម្រោងថវិកាចំណាយនានាពាក់ព័ន្ធនឹងកិច្ចប្រជុំ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានក្រុមការងារត្រូវសុំយោបល់ដឹកនាំផ្ទាល់ពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារ ។

**ប្រការ ៤.-**

ក្រុមការងារអន្តរក្រសួង ត្រូវមានក្រុមលេខាមួយជាជំនួយការ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ប្រធានក្រុមការងារ អាចស្នើសុំមន្ត្រីនៃទីស្តីការក្រសួងមហាផ្ទៃ ឬមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងក្រុមការងារ ឱ្យជួយការងារតាមការចាំបាច់ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ ។

**ប្រការ ៥.-**

ក្នុងការសម្របសម្រួលរៀបចំខ្លឹមសារនៃកិច្ចប្រជុំ ក្រុមការងារមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួម តាមការចាំបាច់ ។

**ប្រការ ៦.-**

ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន ។

**ប្រការ ៧.-**

ក្រុមការងារបញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាលរួចរាល់ជាស្ថាពរ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន អភិបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម និងសមាសភាព ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ . ខែ ឧសភា ឆ្នាំ ២០០៩

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ